ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

អគ្គនាយកដ្ឋានពន្ធដារ

លេខ ៤៦៨៩២.....អពដ

L20201116003 | TD9702

ថ្ងៃចន្ទ ៧រោច ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២០

# សេចក្តីជូនដំណឹង

## ស្តីពី

## ការបញ្ឈប់ឱ្យដំណើរការប្រព័ន្ធគ្រប់គ្រងការបង្វិលសងអាករលើតម្លៃបន្ថែម (E-VAT Refund System) ដោយជំនួសមកវិញនូវប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធតាមអនឡាញ (E-Filing System)

អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានកិត្តិយសសូមជម្រាបជូន លោក-លោកស្រីអភិបាល បណ្ណាធិការ ឬកម្មសិទ្ធិករសហគ្រាស និងអ្នកជាប់ពន្ធ ឱ្យបានជ្រាបថា កន្លងមកអគ្គនាយកដ្ឋានពន្ធដារបានដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធគ្រប់គ្រងការបង្វិលសងអាករលើតម្លៃបន្ថែម (E-VAT Refund System) តាមរយៈសេចក្តីណែនាំលេខ ០០១ សហវ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៩។ ក្រោយមក តាមរយៈសេចក្តីណែនាំលេខ ០០៣ សហវ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០ បានផ្តល់ជម្រើសដល់អ្នកជាប់ពន្ធ លើការប្រើប្រាស់ប្រព័ន្ធមួយក្នុងចំណោមប្រព័ន្ធទាំងពីរ ដើម្បីបំពេញកាតព្វកិច្ចដាក់លិខិតប្រកាសពន្ធ។

ដើម្បីពង្រឹងការផ្តល់សេវាជូនអ្នកជាប់ពន្ធឱ្យបានល្អប្រសើរ ធានាបាននូវប្រសិទ្ធភាព តម្លាភាព ភាពងាយស្រួល ឆាប់រហ័សក្នុងការបំពេញកាតព្វកិច្ចដាក់លិខិតប្រកាស និងបង់ពន្ធ អគ្គនាយកដ្ឋានពន្ធដារសម្រេចបញ្ឈប់ឱ្យដំណើរការប្រព័ន្ធគ្រប់គ្រងការបង្វិលសងអាករលើតម្លៃបន្ថែម (E-VAT Refund System) ដោយជំនួសមកវិញនូវប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធតាមអនឡាញ (E-Filing System) ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២១ ខាងមុខនេះតទៅ។ បន្ទាប់ពីនេះ លោក-លោកស្រីអាចប្រើប្រាស់មុខងារ E-VAT Refund នៅក្នុងប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធតាមអនឡាញ (E-Filing System)តែម្តង។

អគ្គនាយកដ្ឋានពន្ធដារសង្ឃឹមយ៉ាងមុតមាំថា លោក-លោកស្រីអភិបាល បណ្ណាធិការ ឬកម្មសិទ្ធិករសហគ្រាស និងអ្នកជាប់ពន្ធទាំងអស់នឹងចូលរួម ព្រមទាំងជំរុញការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធតាមអនឡាញ (E-Filing System) ប្រកបដោយប្រសិទ្ធភាពខ្ពស់។

ប្រតិភូរាជរដ្ឋាភិបាល
ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ

គង់ វិបុល